ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# បទប្បញ្ញត្តិក្នុងការសិក្សាសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

## ប្រការ១ : គោលបំណង

បទប្បញ្ញត្តិនេះ ជានាផ្តល់នូវសមធម៌ យុត្តិធម៌ក្នុងការសិក្សា និងសំដៅជានាឲ្យបាននូវគុណភាពនៃការបណ្តុះបណ្តាលប្រកបដោយក្រមសីលធម៌ សុជីវធម៌ និងវិជ្ជាជីវៈសម្រាប់និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានទាំងអស់។

ការរៀបចំមុខវិជ្ជាបង្រៀនត្រូវបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យ-ភូមិន្ទភ្នំពេញ ។

## ប្រការ២ : លក្ខខណ្ឌនៃមុខវិជ្ជាសិក្សា

១. ដេប៉ាតឺម៉ង់ទាំងអស់សុទ្ធតែមានមុខវិជ្ជាសិក្សារួម និងជម្រើសសិក្សាបរិញ្ញាបត្រសម្រាប់ឆ្នាំសិក្សាមូលដ្ឋាន។

២. មុខវិជ្ជាបង្រៀននីមួយៗអាចផ្តល់ជាតម្លៃក្រេឌីត(Credit)តិច ឬច្រើនទៅតាមសារៈសំខាន់និងតម្រូវការជាក់ស្តែងនៃមុខវិជ្ជាទាំងនោះ។

៣. រាល់ដើមឆ្នាំសិក្សា និស្សិតត្រូវចុះឈ្មោះចូលរៀន និងបង់ថ្លៃសិក្សាតាមការកំណត់របស់សាកលវិទ្យាល័យ។

## ប្រការ៣ : ការសិក្សា

និស្សិតតម្រូវឲ្យរៀនគ្រប់មុខវិជ្ជា និងបំពេញឲ្យគ្រប់ក្រេឌីតទាំងអស់តាមកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលកំណត់ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

## ប្រការ៤ : វត្តមាន

១. សម្រាប់និស្សិតអាហារូបករណ៍គ្រប់ប្រភេទត្រូវចូលសិក្សាឲ្យបានយ៉ាងតិច៨០% និង៧០% សម្រាប់និស្សិតសិក្សាបង់ថ្លៃចំពោះមុខវិជ្ជានីមួយៗ។

២. ចាត់ទុកជាអវត្តមានមានច្បាប់ ក្នុងករណីបានសុំច្បាប់ដែលទទួលបានការយល់ព្រមពីដេប៉ាតឺម៉ង់។ អវត្តមាន មានច្បាប់មិនលើសពី២០%សម្រាប់និស្សិតអាហារូបករណ៍ និងមិនលើស៣០% សម្រាប់និស្សិតបង់ថ្លៃ នៃចំនួនម៉ោងសិក្សាសរុបទាំងអស់ (១៥សប្តាហ៍)។

៣. ចាត់ទុកថា អវត្តមានអត់ច្បាប់ មិនលើសពី១៥% សម្រាប់និស្សិតអាហារូបករណ៍ និងមិនលើសពី២០% សម្រាប់និស្សិតបង់ថ្លៃ។

## ប្រការ៥ : ការប្រឡង

### ១. សម័យប្រឡង

ក. សម័យប្រឡងទាំងអស់នឹងរៀបចំឡើងនៅដំណាច់ឆមាសនីមួយៗ សម្រាប់មុខវិជ្ជាសិក្សាទាំងឡាយនៅក្នុងឆមាសនោះ។

ខ. និស្សិតទាំងអស់ដែលបានគោរពបទប្បញ្ញត្តិ និងបទដ្ឋានផ្សេងៗរបស់សាកលវិទ្យាល័យ (បទប្បញ្ញត្តិក្នុងការសិក្សា, បទបញ្ជាផ្ទៃក្នុង, បទបញ្ជាក្នុងថ្នាក់រៀន, ទីពិសោធន៍, បណ្ណាល័យជាដើម) នឹងបានបំពេញលក្ខខណ្ឌឱ្យចូលប្រឡង។

គ. លទ្ធផលនៃការប្រឡងនឹងប្រកាសក្នុងរយៈពេល ២០ថ្ងៃ ក្រោយសម័យប្រឡង។

ឃ. និស្សិតដែលបានប្រឡងជាប់គ្រប់គ្រេឌីតសិក្សាតាមការកំណត់ក្នុងប្រការ៣ និស្សិតនោះនឹងទទួលបាននូវវិញ្ញាបនបត្រសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងបន្តការសិក្សាតាមមុខជំនាញដែលបានជ្រើសរើសនៅឆ្នាំទី២ ឬអាចយកទៅប្រើប្រាស់តាមតម្រូវការផ្សេងៗដែលអាចប្រើប្រាស់បាន។

**២. ការប្រឡងឡើងវិញ**

ក. និស្សិតដែលអវត្តមានគ្មានច្បាប់ពេលប្រឡងឆមាស ឬប្រឡងធ្លាក់មុខវិជ្ជាណាមួយ ត្រូវប្រឡងមុខវិជ្ជានោះឡើងវិញនៅចុងឆមាសនីមួយៗ ក្នុងរយៈពេលយ៉ាងយូរបំផុត១សប្ដាហ៍ក្រោយពីប្រកាសលទ្ធផល។ លទ្ធផលប្រឡងនោះគឺមានតែជាប់ ឬធ្លាក់។

ខ.និស្សិតដែលបានបំពេញលក្ខខណ្ឌដូចក្នុងប្រការ៤ ហើយអវត្តមាន មានច្បាប់ពេលប្រឡងឆមាសត្រូវបានអនុញ្ញាតឲ្យប្រឡងសងឡើងវិញ។ លទ្ធផលទទួលបានដោយយកពិន្ទុជាក់ស្ដែង(ពិន្ទុប្រឡងបូកនិងពិន្ទុក្នុងថ្នាក់)។

## <u>ប្រការ៦</u> : រយៈពេលសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

១. និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមិនត្រូវបានអនុញ្ញាតឲ្យសិក្សាលើសពីរយៈពេល២ឆ្នាំឡើយ។

២. និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមិនត្រូវបានអនុញ្ញាតឲ្យព្យួរការសិក្សាឡើយ។

## <u>ប្រការ៧</u> : ការប្រគល់វិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

១. ក្រុមប្រឹក្សាបណ្ដុះបណ្ដាលរបស់សាកលវិទ្យាល័យនឹងប្រជុំពិនិត្យសម្រេចលទ្ធផលប្រឡងរបស់និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ហើយនឹងប្រកាសលទ្ធផល(បិទផ្សាយជាសាធារណៈ) មិនឱ្យលើសពី២០ថ្ងៃក្រោយសម័យប្រឡងនីមួយៗ (ប្រឡងឆមាសទី១, ទី២ និងប្រឡងសងឡើងវិញ)។

២. ការប្រគល់វិញ្ញាបនបត្រសិក្សា នឹងត្រូវប្រគល់ជូននិស្សិតដែលជាប់ជាស្ថាពរក្រោយបំពេញលក្ខខណ្ឌសិក្សាតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានា។

## <u>ប្រការ៨</u> : ប្រព័ន្ធផ្តល់ពិន្ទុ និងនិទ្ទេស

**១. ប្រព័ន្ធផ្តល់ពិន្ទុ និងនិទ្ទេសមានដូចខាងក្រោមៈ**

| ពិន្ទុជាភាគរយ | និទ្ទេសជាអក្សរ | និទ្ទេសជាពិន្ទុ | អត្ថន័យនិទ្ទេស |
|---|---|---|---|
| ៨៥% - ១០០% | A | ៤.០០ | ប្រសើរណាស់ |
| ៨០% - ៨៤% | B+ | ៣.៥០ | ល្អណាស់ |
| ៧០% - ៧៩% | B | ៣.០០ | ល្អ |
| ៦៥% - ៦៩% | C+ | ២.៥០ | ល្អបង្គួរ |
| ៥០% - ៦៤% | C | ២.០០ | មធ្យម |
| ៤៥% - ៤៩% | D | ១.៥០ | ខ្សោយ |
| ៤០% - ៤៤% | E | ១.០០ | ខ្សោយណាស់ |
| <៤០% | F | ០.០០ | មិនគ្រប់លក្ខខណ្ឌវាយតម្លៃសិក្សា |

**២. ការវាយតម្លៃការសិក្សារបស់និស្សិត**

លទ្ធផលសិក្សារបស់និស្សិតត្រូវបានវាយតម្លៃតាមឆមាសនីមួយៗ។ ការវាយតម្លៃរបស់និស្សិតថ្នាក់ឆ្នាំសិក្សា មូលដ្ឋានតាមកម្មវិធីដូចខាងក្រោមៈ

ក. វាយតម្លៃក្នុងថ្នាក់រៀនទទួលបានពិន្ទុ៦០% ផ្អែកលើការធ្វើតេស្តក្នុងថ្នាក់ ការងារក្នុងទីពិសោធន៍ សកម្មភាពចូលរួមក្នុងថ្នាក់ កិច្ចការផ្ទះ ការធ្វើបទបង្ហាញផ្ទាល់ក្នុងថ្នាក់ ការធ្វើកិច្ចការស្រាវជ្រាវផ្សេងៗ និងសំណួរពាក់កណ្ដាលឆមាស ។

ខ. វាយតម្លៃនៃការប្រឡងឆមាសទទួលបានពិន្ទុ៤០% និស្សិតត្រូវតែចូលរួមប្រឡងបញ្ចប់ឆមាសនីមួយៗ ។

គ. និស្សិតអវត្តមានពេលប្រឡងឆមាសណាមួយត្រូវតែធ្លាក់ក្នុងឆមាសនោះដោយស្វ័យប្រវត្តិ ទោះបីជាពិន្ទុវាយតម្លៃក្នុងថ្នាក់លើសមធ្យមភាគ(៥០%) ក៏ដោយ ។

**ប្រការ៩ : អាកប្បកិរិយា**

១. និស្សិតទាំងអស់ត្រូវចូលរួមសកម្មភាពសង្គមតាមការចាត់តាំងរបស់សាកលវិទ្យាល័យ និងត្រូវមានអាកប្បកិរិយា សម្តីសម្តៅថ្លៃថ្នូរសមរម្យ មិនរើសអើង មិនប្រកាន់ពូជសាសន៍ ចំពោះមិត្តភក្តិរួមសាលា ចំពោះសាស្ត្រាចារ្យ មន្ត្រីអប់រំរបស់សាកលវិទ្យាល័យ ទាំងនៅក្នុងថ្នាក់ និងក្នុងបរិវេណសាកលវិទ្យាល័យ។ និស្សិតត្រូវថែរក្សាឲ្យបាននូវវប្បធម៌ និងប្រពៃណីជាតិឲ្យបានល្អ ។

២. និស្សិតតម្រូវឲ្យមានភាពស្មោះត្រង់ គោរពកម្មសិទ្ធិបញ្ញា មិនលួចចម្លងស្នាដៃអ្នកផ្សេង មិនលួចចម្លងកិច្ចការគ្នាទាំងពេលរៀន និងពេលប្រឡងគ្រប់ប្រភេទ មិនប្រើប្រាស់ទូរស័ព្ទដៃ ឬម៉ាស៊ីនកុំព្យូទ័រ គ្រប់ប្រភេទដែលសាស្ត្រាចារ្យមិនអនុញ្ញាត ។ល។

៣. និស្សិតត្រូវគោរពតាមរាល់បទប្បញ្ញត្តិផ្សេងៗដែលរៀបចំឡើងដោយសាកលវិទ្យាល័យ មហាវិទ្យាល័យ វិទ្យាស្ថាន មជ្ឈមណ្ឌល ដេប៉ាតឺម៉ង់ បណ្ណាល័យ ការិយាល័យ និងផ្នែកផ្សេងៗទៀតរបស់សាកលវិទ្យាល័យ។

៤. និស្សិតត្រូវស្លៀកពាក់ឲ្យបានសមរម្យ

ក. និស្សិតនារី អាវផ្ទៃមេឃ សំពត់ក្រោមក្បាលជង្គង់ ពណ៌ខៀវទឹកប៊ិចក្រម៉ៅ ឬខ្មៅ។

ខ. និស្សិតបុរស អាវផ្ទៃមេឃ ខោជើងវែង ពណ៌ខៀវទឹកប៊ិចក្រម៉ៅ ឬខ្មៅ។

គ. និស្សិតទាំងពីប្រភេទមិនត្រូវលាបពណ៌សក់ ចំពោះនិស្សិតប្រុសត្រូវកាត់សក់ខ្លីសមរម្យ ។

៥. និស្សិតត្រូវស្រឡាញ់ថែរក្សាទ្រព្យសម្បត្តិសាកលវិទ្យាល័យដូចជារបស់ខ្លួនដែរ ត្រូវចូលរួមរក្សាសណ្តាប់ធ្នាប់ ថែរក្សាអនាម័យ និងបរិស្ថានល្អក្នុងថ្នាក់រៀន និងទីតាំងផ្សេងៗទៀតក្នុងបរិវេណសាកលវិទ្យាល័យ ជាពិសេសជួយកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច។

៦. ការជក់បារី ការវាយខាន និងបង្កឧបសគ្គដល់ការរៀនសូត្ររបស់អ្នកដទៃ ត្រូវបានហាមឃាត់ទៅតាមទីកន្លែងមួយចំនួនដូចជាថ្នាក់រៀន ទីពិសោធន៍ បណ្ណាល័យ ការិយាល័យនិងកន្លែងផ្សេងៗទៀតក្នុងបរិវេណសាកលវិទ្យាល័យ។

៧. ការលួចបន្លំនិងកេងប្រវ័ញ្ចទ្រព្យសម្បត្តិសាកលវិទ្យាល័យរបស់និស្សិត ត្រូវបានហាមឃាត់ជាដាច់ខាត ហើយនឹងត្រូវទទួលការវិនិច្ឆ័យពីក្រុមប្រឹក្សាវិន័យរបស់សាលា។

៨. ល្បែងស៊ីសង ដាក់ប្រាក់ ឬមិនដាក់ប្រាក់ មិនអនុញ្ញាតឲ្យកើតមានក្នុងបរិវេណសាកលវិទ្យាល័យឡើយ ។

៩. និស្សិតត្រូវផ្តល់ពត៌មានដល់ការិយាល័យសិក្សា បើមានការផ្លាស់ប្តូរអាស័យដ្ឋានរបស់ខ្លួន។

១០. និស្សិតត្រូវបានហាមឃាត់ក្នុងការយកអាវុធ គ្រឿងផ្ទុះ គ្រឿងញៀនចូលក្នុងបរិវេណសាកលវិទ្យាល័យ និងហាមប្រើប្រាស់ទូរស័ព្ទដៃក្នុងម៉ោងរៀន។

១១. និស្សិតហាមទទួលទានភេសជ្ជៈប៉ូវកម្លាំង និងគ្រឿងស្រវឹងផ្សេងៗក្នុងបរិវេណសាកលវិទ្យាល័យ ដូចសេចក្តីណែនាំលេខ ៧១ អយក សណន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា។

និស្សិតដែលបានប្រព្រឹត្តិផ្ទុយពីបទប្បញ្ញត្តិទាំងនេះត្រូវចាត់ទុកថា បានរំលោភលើបទបញ្ជារបស់សាកលវិទ្យាល័យ និស្សិតទាំងនោះនឹងត្រូវបញ្ឈប់ពីការប្រឡង ឬដាក់ជូនក្រុមប្រឹក្សាវិន័យពិនិត្យ និងសម្រេច ។

**ប្រការ១០ : ក្រុមប្រឹក្សាវិន័យ**

១. ក្រុមប្រឹក្សាវិន័យមួយនឹងត្រូវបានបង្កើតឡើង ហើយកោះប្រជុំទៅតាមស្ថានការណ៍ដែលមានករណីខុសឆ្គងរបស់និស្សិត។

២. សមាសភាពនៃក្រុមប្រឹក្សាវិន័យនេះរួមមាន៖

- គណៈគ្រប់គ្រងសាកលវិទ្យាល័យ
- ព្រឹទ្ធបុរសមហាវិទ្យាល័យ ឬនាយកវិទ្យាស្ថាន ដែលពាក់ព័ន្ធ
- ប្រធានការិយាល័យសិក្សា
- ប្រធានដេប៉ាតឺម៉ង់ ដែលពាក់ព័ន្ធ
- តំណាងសមាគមនិស្សិត។

**ប្រការ១១ : ការលុបឈ្មោះ**

និស្សិតអាចត្រូវបញ្ឈប់ការសិក្សា ដោយលុបឈ្មោះចេញពីបញ្ជីនិស្សិតតាមលក្ខខណ្ឌដូចខាងក្រោម៖

១. មិនបានបំពេញគ្រប់លក្ខខណ្ឌនៃការសិក្សា។

២. ខុសវិន័យរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង)។

៣. ប្រព្រឹត្តបទល្មើសផ្សេងៗ។

ថ្ងៃសុក្រ ៤កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥

**សាកលវិទ្យាធិការ**

**សាស្ត្រាចារ្យ ជេត ជាលី**